# ទស្សនៈទានថែទាំនិងសុខុមាលភាពក្នុងរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅកម្ពុជា

ការចូលរួមដ៏ពេញលេញរបស់ស្ត្រី គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះកិច្ចខិតខំប្រឹងប្រែងកសាងនិងរក្សាសន្តិភាព ដែលបានទទួលស្គាល់ដោយរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ( WPS ) ក៏ដូចជារបកគំហើញនៃការសិក្សាស្រាវជ្រាវនានា។[១] ទោះជាយ៉ាងណាក៏ដោយ ក៏ស្ត្រីនៅតែបន្តមានភាពជាតំណាងតិចតួចនៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ។ ឧទាហរណ៍ នៅក្នុងបេសកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ស្ត្រីមានត្រឹមតែ ៧.៨% នៃបុគ្គលិកឯកសណ្ឋានប៉ុណ្ណោះ។ នេះបើយោងតាមស្ថិតិចុងក្រោយពីនាយកដ្ឋានប្រតិបត្តិការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។ ឧបសគ្គដ៏ធំបំផុតមួយចំពោះការចូលរួមរបស់ស្ត្រី គឺតួនាទីថែទាំដែលមានលក្ខណៈយេនឌ័រ មិនបានផ្តល់តម្លៃ និងត្រូវបានមើលរំលង។

ការស្រាវជ្រាវថ្មីមួយដឹកនាំដោយមជ្ឈមណ្ឌលសន្តិភាពនិងសន្តិសុខសកល ( Monash GPS ) បង្ហាញថា អ្នកកសាងសន្តិភាពជាស្ត្រីតែងតែមានផលវិបាករក្សានិងត្រឡប់ចូលបម្រើការងារវិញនៅពេលដែលពួកគេក្លាយជាម្តាយ ហើយជាញឹកញាប់មានអារម្មណ៍ថាមិនសូវទទួលបានការឱ្យតម្លៃពីអ្នកគ្រប់គ្រងនិងក្រុមការងារ។[២] ភាពងាយរងគ្រោះរបស់ស្ត្រីក្នុងវិស័យនេះ មិនត្រឹមតែជះឥទ្ធិពលដល់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងក្នុងដំណើរការកសាងនិងរក្សាសន្តិភាពនិងសន្តិសុខផងដែរ ពីព្រោះវាបាន៖

- ជំរុញឱ្យមានកង្វះភាពជាតំណាងរបស់ស្ត្រី
- កម្រិតភាពចម្រុះ ដែលប៉ះពាល់ដល់ការឆ្លើយតប និងប្រសិទ្ធភាព
- រក្សាវប្បធម៌កន្លែងធ្វើការងារដែលមានគ្រោះថ្នាក់ដល់ការមិនផ្តល់តម្លៃដល់ការអនុវត្ត និងទំនាក់ទំនងការងារថែទាំ រួមទាំងការថែទាំខ្លួនឯង និងការថែទាំអ្នកដទៃ។ ការណ៍នេះនឹងរួមចំណែកបង្កើនភាពស្ត្រេស ភាពតានតឹង និងភាពនឿយហត់នឹងការងារ។

| ៦១% | ៧០% | ៧៨% | ៨០% | ៨៨% | ៨៩% |
|---|---|---|---|---|---|
| បាននិយាយថា វាពិបាកសម្រាប់មនុស្សដែលមានភារកិច្ចថែទាំក្នុងការធ្វើការនៅវិស័យនេះ។ | បាននិយាយថា វាមានផលប៉ះពាល់ទៅដល់ឱកាសនៃទទួលបានការបណ្តុះបណ្តាល (១៧% បាននិយាយថា មានផលប៉ះពាល់យ៉ាងខ្លាំង)។ | បានចាកចេញ ឬផ្លាស់ប្តូរការងាររបស់ពួកគេក្នុងវិស័យសន្តិភាព (មានបន្ថែម ៩% បាននិយាយថា "អត់ទេ ប៉ុន្តែខ្ញុំក៏ធ្លាប់បានគិតថានឹងឈប់ដែរ")។ | បាននិយាយថា វាផលប៉ះពាល់ទៅដល់ឱកាសនៅក្នុងការកសាងបណ្តាញ (១៤% បាននិយាយថា មានផលប៉ះពាល់យ៉ាងខ្លាំង)។ | បាននិយាយថា វាផលប៉ះពាល់ទៅដល់ឱកាសចូលរួមបេសកកម្ម ឬទីតាំងដែលពួកគេអាចធ្វើការងារបាន (៤១% បាននិយាយថា មានផលប៉ះពាល់យ៉ាងខ្លាំង)។ | បាននិយាយថា វាមានផលប៉ះពាល់ដល់ការរីកចម្រើននៃអាជីពរបស់ពួកគេ (២៧% បាននិយាយថា មានផលប៉ះពាល់យ៉ាងខ្លាំង)។ |



នៅពេលដែលស្ត្រីដែលមានតួនាទីថែទាំមិនត្រូវបានយកចិត្តទុកដាក់ពីសំណាក់ការងារសន្តិភាព និងសន្តិសុខ វាធ្វើឱ្យប៉ះពាល់ទៅដល់របៀបនៃការបង្កើតទស្សនទានស្តីពីសន្តិសុខ និងសន្តិភាព អទិភាពនៃសន្តិសុខថាតើវាជារបស់នរណា និងប្រភេទនៃការកសាងសន្តិភាពបែបណា។ វាក៏នាំឱ្យកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសន្តិភាព និងសន្តិសុខមិនសូវមានបរិយាបន្ន និងភាពចម្រុះ ដែលទំនងជាមិនអាចឆ្លើយតបទៅនឹងតម្រូវការបែបចម្រុះ និងមិនសូវមានលទ្ធភាពទទួលបានទំនុកចិត្ត និងការជឿជាក់ពីសាធារណៈជនឱ្យបានទូលំទូលាយ។ ផ្ទុយទៅវិញ នៅពេលដែលស្ត្រីមានតួនាទីថែទាំត្រូវបានគាំទ្រ និងអាចចូលរួមក្នុងការងារកសាងនិងរក្សាសន្តិភាព និងសន្តិសុខ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងអាចឆ្លើយតបបានកាន់តែប្រសើរឡើងទៅនឹងបញ្ហាប្រឈមដែលមានភាពស្មុគស្មាញ និងមានទំនាក់ទំនងគ្នាទៅវិញទៅមក ដោយសារពួកគេអាចប្រើប្រាស់ជំនាញ ចំណេះដឹង និងបណ្តាញដ៏សម្បូរបែប។

“ អ្វីដែលយើងត្រូវការបំផុតនោះគឺ ពិភពលោកមួយដែលប្រសើរសម្រាប់មនុស្សគ្រប់រូបទាំងអស់ មិនមែនសម្រាប់តែមួយចំណែកតូចនោះទេ។  ការណ៍នេះត្រូវការយើងទាំងអស់គ្នាក្នុងសង្គម រួមគ្នាដោះស្រាយ។   ...  យើងចង់កសាងវិថីមួយដែលប្រសើរសម្រាប់ស្ត្រីនៅពេលបច្ចុប្បន្ននិងអនាគត។ ហើយមិនមែនសម្រាប់តែស្ត្រីនោះទេ ប៉ុន្តែសម្រាប់យើងទាំងអស់គ្នាគ្រប់រូប។”

ការងារថែទាំ សំដៅទៅលើសកម្មភាពសំខាន់ៗដែលជាទូទៅមិនបានទទួលប្រាក់កម្រៃ ដែលអ្នកផ្តល់ការថែទាំធ្វើសម្រាប់អ្នកដទៃ និងខ្លួនឯង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់លាក់ណាមួយ។ ការងារថែទាំនេះជាធម្មតារួមបញ្ចូល ការថែទាំកុមារ និងសមាជិកគ្រួសារផ្សេងទៀត ហើយអាចរួមបញ្ចូលការងារជាក់ស្តែងដូចជាការចម្អិនអាហារ ឬការងារផ្ទះ ឬការផ្តល់ការថែទាំរាងកាយ និងផ្ទាល់ខ្លួនសម្រាប់នរណាម្នាក់។



ការស្រាវជ្រាវថ្មីនេះ ស្តីពីទស្សនៈទានថែទាំនិងសុខមាលភាពនៅក្នុងរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងប្រទេសកម្ពុជា គឺជាកិច្ចសហការរវាងអង្គការនារីដើម្បីសន្តិភាព និងមជ្ឈមណ្ឌលសន្តិភាព និងសន្តិសុខសកល Monash GPS ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ដែលរួមមានតំណាងក្រសួងកិច្ចការនារី មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងទ័ពរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម តំណាងអង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិ។ ការស្រាវជ្រាវនេះបានគូសបញ្ជាក់ពីសារៈសំខាន់ដែលស្ត្រីអាចមាននិងអាចធ្វើបាននៅក្នុងការងារសន្តិសុខនិងសន្តិភាព។ នេះមិនមែនដោយសារតែបទពិសោធន៍ និងតម្រូវការពិសេសរបស់ពួកគេតែប៉ុណ្ណោះ ប៉ុន្តែ ដោយសារភាពចម្រុះនៃជំនាញ ចំណេះដឹង និងសមត្ថភាពដែលពួកគេមានផងដែរ។ វាក៏បានគូសបញ្ជាក់ពីឧបសគ្គសនានា ចំពោះការចូលរួមរបស់ស្ត្រីដែលកើតឡើងដោយសារការងារថែទាំ រួមមាន៖

- លក្ខណៈយេនឌ័រនៃការងារថែទាំមិនមានប្រាក់កម្រៃ - ស្ត្រីទទួលរ៉ាប់រងការងារថែទាំភាគច្រើន ( ៩០% នៅក្នុងប្រទេសកម្ពុជា )[៣] មានន័យថាស្ត្រីមានពេលវេលាតិច លទ្ធភាពតិច និងធនធានតិច។
- ការសន្មត់តាមបទដ្ឋានយេនឌ័រអំពីការងារថែទាំមិនមានប្រាក់កម្រៃ និង ការងារសន្តិភាពនិងសន្តិសុខថាមិនស៊ីសង្វាក់គ្នាទេ។
- ការលំអៀងនៃភាពជាម្តាយ ( ការសន្មត់អំពីសមត្ថភាព និងការតាំងចិត្តរបស់ម្តាយ ) និងការរើសអើងលើស្ត្រីដែលមានតួនាទីថែទាំ អាចកាត់បន្ថយការចូលរួម ការជ្រើសរើស ការរក្សាទុក ការបណ្តុះបណ្តាល និងការតំឡើងដំណែងរបស់ស្ត្រី។
- ឧបសគ្គជាក់ស្តែង ( ដូចជា ភាពមានកម្រិតដើម្បីទទួលបានការថែទាំកុមារដែលមានតម្លៃសមរម្យ ឬកង្វះភាពបត់បែននៅកន្លែងធ្វើការ )
- កង្វះការគាំទ្រពីស្ថាប័ន។

Lorem ipsum

## ការស្រាវជ្រាវនេះបានផ្តល់នូវអនុសាសន៍ដើម្បីគាំទ្រអ្នកមានតួនាទីថែទាំ ឱ្យកាន់តែប្រសើរឡើងក្នុងការងារសន្តិភាព និងសន្តិសុខ ដូចខាងក្រោម៖

# អនុសាសន៍

១ ទទួលស្គាល់និងផ្តល់តម្លៃដល់ការងារថែទាំ ថាមានសារៈសំខាន់ចំពោះសុខុមាលភាព សង្គមភាពធន់ និងការអភិវឌ្ឍន៍

២ លើកកម្ពស់ការយល់ដឹងអំពីការងារថែទាំថាជាទំនួលខុសត្រូវរួម និងទាមទារវិធីសាស្ត្រដែលមានការចូលរួមរបស់សង្គមទាំងមូល

៣ លើកកម្ពស់ក្រមសីលធម៌នៃការថែទាំក្នុងការងារសន្តិភាពនិងសន្តិសុខ ដោយផ្សាភ្ជាប់ការថែទាំអ្នកដទៃ កាតព្វកិច្ចនៃការថែទាំ និងការថែទាំខ្លួនឯង

៤ វិនិយោគលើគោលនយោបាយ និងថវិកាឆ្លើយតបយេនឌ័រ និងប្រព័ន្ធគាំពារសង្គមដែលឆ្លើយតបយេនឌ័រ

៥ ធានាឱ្យមានលទ្ធភាពទទួលបានការថែទាំកុមារ និងយន្តការគាំទ្រ (ផ្លូវការ និងក្រៅផ្លូវការ) សម្រាប់អ្នកថែទាំ

៦ ពង្រីកការបណ្តុះបណ្តាលស្តីពីយេនឌ័រ និងដោះស្រាយភាពលំអៀងលើភាពជាម្តាយនៅក្នុងស្ថាប័នដែលចូលរួមក្នុងការងារសន្តិភាព និងសន្តិសុខ

៧ ទទួលស្គាល់ និងគាំទ្រតួនាទីសំខាន់របស់ស្ត្រីក្នុងការងារសន្តិភាព និងសន្តិសុខជាផ្លូវការ និងនៅមូលដ្ឋាន

ការគាំទ្រកាន់តែប្រសើរឡើងសម្រាប់អ្នកមានតួនាទីថែទាំ នឹងបង្កើនការចូលរួមដ៏ពេញលេញរបស់ស្ត្រីក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងនិងរក្សាសន្តិភាពនិងសន្តិសុខ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះផងដែរ។ វាក៏នឹងជំរុញកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងសមភាពយេនឌ័រ។ ផលប៉ះពាល់ដល់មនុស្សនិងហិរញ្ញវត្ថុនឹងអាចមានច្រើន ប្រសិនបើមិនដោះស្រាយបញ្ហានេះ រួមមាន៖ វិសមភាពយេនឌ័រធ្វើឱ្យសេដ្ឋកិច្ចខាតរហូតដល់ ២០% នៃផលិតផលក្នុងស្រុកសរុប[4] ខណៈដែលការចំណាយលើជម្លោះប្រដាប់អាវុធពិភពលោកឆ្នាំ ២០២៣ មានចំនួន ១៩.១ ពាន់ពាន់លានដុល្លារ។[5]

ការយកចិត្តទុកដាក់ចំពោះការងារថែទាំមានប្រយោជន៍សម្រាប់ទាំងបុរស និងអ្នកដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ ដែលមានទំនួលខុសត្រូវក្នុងការថែទាំ (ដែលជារឿយៗត្រូវបានគេមើលរំលង) ក៏ដូចជាតម្រូវការថែទាំផងដែរ។ ជាងនេះទៅទៀត ការយកចិត្តទុកដាក់កាន់តែទូលំទូលាយចំពោះការថែទាំអាចបង្កប់នូវក្រមសីលធម៌នៃការថែទាំក្នុងការងារសន្តិភាព និងសន្តិសុខ ដែលជំរុញគោលនយោបាយ និងការអនុវត្តន៍ដែលមានបរិយាបន្ន និងឆ្លើយតបកាន់តែមានប្រសិទ្ធភាព ព្រមទាំងការយល់ដឹងអំពីភាពពឹងពាក់គ្នាទៅវិញទៅមករវាងមនុស្សផងដែរ។ វាក៏អាចជួយគូសបញ្ជាក់អំពីសារៈសំខាន់នៃការងារថែទាំ រួមទាំង ការថែទាំខ្លួនឯង ការថែទាំអ្នកដទៃ និងកាតព្វកិច្ចនៃការថែទាំ ព្រមទាំងទទួលស្គាល់ពីសារៈសំខាន់ដ៏សំខាន់នៃការងារថែទាំចំពោះសន្តិសុខសង្គម សន្តិភាព និងវិបុលភាព។

> ការងារថែទាំមានសារៈសំខាន់ណាស់ក្នុងការទ្រទ្រង់សុខុមាលភាព និងការរស់រានមានជីវិតរបស់គ្រួសារ សហគមន៍ និងសង្គម ហើយជាពិសេសមានសារៈសំខាន់ក្នុងអំឡុងពេល និងក្រោយជម្លោះ និងវិបត្តិ។




ការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ គឺស្តែងចេញតាមរយៈការអនុម័តផែនការសកម្មភាពថ្នាក់តំបន់ស្តីពីរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដោយសមាគមន៍ប្រជាជាតិអាស៊ាន ក្នុងឆ្នាំ ២០២២ ក្រោមការដឹកនាំរបស់ប្រទេសកម្ពុជា (អាស៊ាន ២០២២) ។ ការប្តេជ្ញាចិត្តទៅលើការថែទាំ និងគាំទ្រទៅលើអ្នកដែលតួនាទីថែទាំ គឺបានបង្ហាញតាមរយៈពានរង្វាន់ថ្មីៗចំនួន ពីរដែលផ្តល់ជូនក្រសួងកិច្ចការនារី ដូចជា ពានរង្វាន់សេដ្ឋកិច្ចដែលគិតគូរសុខុមាលភាពអាស៊ានឆ្នាំ២០២៤ និងពានរង្វាន់ទទួលស្គាល់ដោយតំបន់អាស៊ីប៉ាស៊ីហ្វិកស្តីពីជើងឯកលើការងារថែទាំនិងសុខុមាលភាពក្នុងតំបន់ឆ្នាំ២០២៤។ ប្រទេសកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងប្រតិបត្តិការរក្សាសន្តិភាពនិងសុខសហប្រជាជាតិ ដោយឈរក្នុងចំណាត់ថ្នាក់ទីបីនៃការបញ្ជូនទាហានក្នុងចំណោមសមាជិកអាស៊ាន[៦] ហើយនៅតែប្តេជ្ញាចិត្តក្នុងការបង្កើនការចូលរួមរបស់ស្ត្រី។ លើសពីនេះ ស្ត្រីនៅក្នុងកិចការងារសង្គមស៊ីវិល ក៏មានសារៈសំខាន់ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ យុត្តិធម៌ និងការអភិវឌ្ឍន៍។ នេះជាពេលវេលាដ៏សមស្របសម្រាប់កម្ពុជាដើម្បីក្លាយជាអ្នកដឹកនាំក្នុងការលើកកម្ពស់នវានុវត្តន៍និងភាពជោគជ័យនៃការកសាងសន្តិភាព អនុវត្តរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដូចជាលើកម្ពស់ការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ជាពិសេស គោលដៅទី ៥.៤ ដែលអំពាវនាវឲ្យទទួលស្គាល់ ផ្តល់តម្លៃ និងគាំទ្រការងារថែទាំ។

ការងារថែទាំអាចទប់ស្កាត់ជម្លោះ និងកសាងសន្តិភាព៖ ការបំពេញតម្រូវការចាំបាច់ ការតភ្ជាប់ ការការពារ និងការទទួលខុសត្រូវចំពោះអ្នកដទៃ។

---

[១] Davies, S. and True, J. (2018) The Oxford handbook of women, peace, and security. Oxford University Press..

[២] Monash GPS, University of Warwick, RMIT, University of Sydney [with Department of Foreign Affairs and Trade (Australia)), UN Research Institute for Social Development (UNRISD), Swisspeace, Geneva Centre for Security Sector Governance (DCAF), Saferworld, International Peace Institute (IPI), UN Department of Peace Operations (UNDPO), UN Women, African Union Commission (AUC), Kofi Annan International Peacekeeping Training Centre (KAIPTC)] (2024) "Who Cares in Peacebuilding: Building Sustainable Peace and Advancing Gender Equality through Support for Peacebuilders with Caring Responsibilities." Monash GPS et al. https://www.monash.edu/arts/global-peace-security/news-and-events/articles/2024/who-cares-in-peacebuilding

[៣] International Bank for Reconstruction and Development (IBRD)/World Bank (2024) Supply of and Demand for Accessible and Affordable Childcare Services in Cambodia. IBRD/World Bank. https://documents1.worldbank.org/curated/en/099092424012023366/pdf/P1781341947932027l8f841b6a877d0c5a4.pdf

[៤] Pennings, S. (2022) "A Gender Employment Gap Index (GEGI): A Simple Measure of the Economic Gains from Closing Gender Employment Gaps, with an Application to the Pacific Islands", Policy Research Working Paper 9942, World Bank Group. https://openknowledge.worldbank.org/server/api/core/bitstreams/661cbd80-45a4-5bd9-b90e-71f41ae11841/content

[៥] Institute for Economics & Peace (IEP) (2024). Global Peace Index 2024: Measuring Peace in a Complex World. IEP. https://www.economicsandpeace.org/wp-content/uploads/2024/06/GPI-2024-web.pdf

[៦] United Nations Department of Peace Operations (UNDPO) (2025) "Contribution of Uniformed Personnel to UN by Country and Personnel Type: Experts on Mission, Formed Police Units, Individual Police, Staff Officer, and Troops As of 31/01/2025", UNDPO. https://peacekeeping.un.org/sites/default/files/01_contributions_to_un_peacekeeping_operations_by_country_and_post_82_january_2025.pdf